# ទំនុកដំកើង ៩៩

អ្នកនិពន្ធ លឿង សុខលី

**សេចក្តីណែនាំៈ**

ទំនុកដំកើង ៩៣, ៩៧ និង ៩៩ ចាប់ផ្តើមដោយឃ្លាដូចគ្នាថា «ព្រះយេហូវ៉ាទ្រង់គ្រប់គ្រង»។ ដោយសារព្រះយេហូវ៉ាទ្រង់គ្រប់គ្រង នោះទំនុកដំកើង ៩៣ បន្តនៅក្នុងខ.១ ថា លោកិយនោះនឹងបានតាំងមាំមួន និងរង្គើរមិនបានឡើយ។ ឯទំនុកដំកើង ៩៧ បន្តថា គួរឲ្យផែនដីអរសប្បាយឡើង។ ប៉ុន្តែដោយឡែកទំនុកដំកើង ៩៩ នេះបន្តថា ត្រូវឲ្យអស់ទាំងសាសន៍ញាប់ញ័រ និងផែនដីកក្រើករំពើកចុះ។ ទំនុកដំកើង ៩៩ មានឃ្លាសំខាន់ «ត្បិតទ្រង់បរិសុទ្ធ» (ខ. ៣, ៥, ៩) លេចឡើងបីដងដែលធ្វើឲ្យយើងងាយស្រួលក្នុងការយល់គំនិតចំបងនិងបែងចែករចនាសម្ព័ន្ធនៃទំនុកដំកើងនេះ។ ដោយព្រោះព្រះជាស្តេចដ៏បរិសុទ្ធគ្រប់គ្រងនិងវិនិច្ឆ័យផែនដីនិងជាតិសាសន៍ទាំងអស់ដោយសេចក្តីស្រលាញ់ យុត្តធម៌ សេចក្តីសុចរិតនិងទៀងត្រង់ អត់ទោសនិងឆ្លើយតបចំពោះសេចក្តីអធិស្ឋាន នោះមនុស្សគួរតែថ្វាយបង្គំ និងសរសើរដល់ព្រះនាមទ្រង់។

**រចនាសម្ព័ន្ធៈ**

ខ. ១-៣ បរិយាយអំពីព្រះអង្គគឺជាមហាក្សត្របរិសុទ្ធគ្រប់គ្រងលើផែនដីទាំងមូល

ខ. ៤-៥ បរិយាយអំពីព្រះអង្គគឺជាមហាក្សត្រវិនិច្ឆ័យប្រកបដោយព្រះគុណ

ខ. ៦-៩ បរិយាយអំពីទំនាក់ទំនងរវាងរាស្រ្តរបស់ព្រះនិងព្រះនៅក្នុងសេចក្តីអធិស្ឋាន។

**ខ. ១-៣** *ត្រូវឲ្យអស់ទាំងសាសន៍ញាប់ញ័រ* (ខ. ១) នៅទីនេះមានពេញទៅដោយភាពឧត្តុង្គឧត្តមរបស់មហាក្សត្រដ៏បរិសុទ្ធមួយអង្គ ដែលអស់ទាំងសាសន៍និងផែនដីត្រូវញាប់ញ័រនិងកក្រើករំពើកនៅចំពោះទ្រង់។ ទ្រង់គឺជាមហាក្សត្រដ៏បរិសុទ្ធ មានព្រះនាមធំប្រសើរ គ្រប់គ្រង និងខ្ពស់លើសអស់ទាំងគ្រប់ជាតិសាសន៍នៅលើផែនដី។

*ចេរូប៊ីន (ខ. ១)* គឺជារូបសត្វដែលមានជើងបួននិងស្លាបពីរនៅពីលើហិបសញ្ញារបស់ព្រះ។ ចេរូប៊ីន តំណាងឲ្យសត្វដែលការពាររាជ្យបល្ល័ង្ករបស់ស្តេចឬព្រះ។ *ទ្រង់គង់ពីលើចេរូប៊ីន* (ខ.១) គឺជារូបភាពអំពីព្រះអង្គគង់លើរាជ្យបល្ល័ង្ករបស់ទ្រង់ ហើយចេរូប៊ីនគឺជាអ្នកការពាររាជ្យបល្ល័ង្ករបស់ទ្រង់។ បន្ទាប់ពីអ័ដាមនិងអេវ៉ាបាបធ្វើបាប ព្រះបានបណ្តេញពួកគេចេញពីសួនច្បារអេដែន ហើយទ្រង់បានដាក់ចេរូប៊ីនដើម្បីការពារក្រែងពួកគេវិលមកឯដើមជីវិត (សូមមើលលោកុប្បត្តិ ៣:២២-២៤)។ រូបភាពចេរូប៊ីននេះធ្វើឲ្យយើងគិតអំពីភាពស្រដៀងគ្នាទៅក្នុងវប្បធម៌ខ្មែររបស់យើង។ នៅក្នុងវប្បធម៌ខ្មែរ យើងឃើញមានរូបពស់ពិសពីរឬច្រើនជាងនេះត្រូវបានដាក់លំអរនៅលើបល្ល័ង្ករបស់ស្តេចឬអាទិទេព និងនៅសងខាងផ្លូវចូលក្នុងទីវត្តអារាមនិងប្រាសាទនានា។ នៅក្នុងគំនិតរបស់ជនជាតិខ្មែរគិតថា រូបពស់ទាំងនោះមានតួនាទីការពាររាជ្យបល្ល័ង្ករបស់ស្តេចឬអាទិទេពរបស់ពួកគេ។

*ព្រះយេហូវ៉ាទ្រង់ធំប្រសើរក្នុងក្រុងស៊ីយ៉ូន (ខ. ២)* ក្រុងស៊ីយ៉ូនសំដៅលើក្រុងយេរូសាឡឹម ហើយទាក់ទងនឹងហិបសញ្ញាដែលមានចេរូប៊ីន (ខ. ១) ការថ្វាយបង្គំនៅទៀបកំណល់កល់ព្រះបាទទ្រង់ (ខ. ៥) និងភ្នំបរិសុទ្ធរបស់ទ្រង់ (ខ. ៩)។ ដូច្នេះ អ៊ីស្រាអែលបានថ្វាយបង្គំព្រះដ៏ធំប្រសើរនៅក្នុងព្រះវិហារក្រុងយេរូសាឡឹមដែលមានហិបសញ្ញានៅចំពោះមុខពួកគេ។

*ត្បិតទ្រង់បរិសុទ្ធ (ខ. ៣, ៥, ៩)* បរិសុទ្ធគឺជាពាក្យសង្កត់ធ្ងន់លើគម្លាតរវាងព្រះនិងមនុស្ស។ ព្រះបរិសុទ្ធមនុស្សមានបាប ហើយនគររបស់ព្រះនៅអស់កល្បជានិច្ច ផែនដីរបស់មនុស្សពុករលួយ។ ដូច្នេះ មនុស្សមិនអាចរស់នៅក្នុងនគររបស់ព្រះបានទេ។ ប៉ុន្តែទំនុកដំកើងនេះបង្ហាញប្រាប់យើងថា ព្រះបានផ្សាភ្ជាប់គម្លាតនោះរួចជាស្រេច ដើម្បីឲ្យមនុស្សមានបាបអាចរស់នៅក្នុងនគររបស់ទ្រង់ ថ្វាយបង្គំ និងសរសើរតម្កើងដល់ព្រះនាមទ្រង់បាន។

**ខ. ៤-៥** មហាក្សត្រគ្រប់គ្រងដោយច្បាប់របស់ទ្រង់ ហើយទ្រង់វិនិច្ឆ័យដោយផ្អែកលើច្បាប់របស់ទ្រង់ផ្ទាល់។ មហាក្សត្រស្រលាញ់និងវិនិច្ឆ័យតាមសេចក្តីយុត្តិធម៌និងសេចក្តីសុចរិត តាំងឲ្យមានសេចក្តីទៀងត្រង់ក្នុងចំណោមរាស្ត្ររបស់ទ្រង់។ ច្បាប់និងការវិនិច្ឆ័យរបស់មហាក្សត្រមិនពឹងផ្អែកលើសមត្ថភាពរបស់រាស្ត្ររបស់ទ្រង់ដើម្បីបំពេញតាមច្បាប់របស់ទ្រង់នោះទេ ប៉ុន្តែបង្ហាញឲ្យយើងឃើញអំពីចរឹតលក្ខណៈរបស់ទ្រង់ផ្ទាល់វិញ ថាទ្រង់គឺជាមហាក្សត្របរិសុទ្ធពេញដោយព្រះគុណ ដែលស្រលាញ់សេចក្តីយុត្តិធម៌និងសេចក្តីទៀងត្រង់។

*ថ្វាយបង្គំនៅទៀបកំណល់កល់ព្រះបាទទ្រង់ (ខ. ៥)* នៅក្នុងវប្បធម៌ខ្មែរឬជាតិសាសន៍ខ្លះទៀត នៅពេលប្រជារាស្ត្រធម្មតាចូលគាល់មហាក្សត្ររបស់ខ្លួន នោះយើងត្រូវតែលុតក្រាបសំពះដល់ទ្រង់ ដើម្បីបង្ហាញអំពីការចុះចូលនិងការគោរពដល់ទ្រង់។ ទំនុកដំកើង ៩៩ នេះប្រាប់យើងថា ដោយសារព្រះអង្គគឺជាមហាក្សត្រដ៏បរិសុទ្ធ នោះយើងគួរតែថ្វាយបង្គំទ្រង់ដោយបង្ហាញការចុះចូល ការស្ញែងខ្លាច ការញាប់ញ័រនៅចំពោះទ្រង់។

ពួកអ៊ីស្រាអែលបានគិតថា ហិបសញ្ញាគឺជាកំណល់កល់បល្ល័ង្ករបស់ព្រះដែលមើលមិនឃើញ (សូមមើលនិក្ខមនំ ២៥:១០-២២)។ កំណល់កល់គឺជាផ្នែកសំខាន់របស់បល្ល័ង្ក ដែលតំណាងឲ្យការចូលទៅដល់ស្តេចយ៉ាងជិតបំផុត។ ហើយរូបភាពកំណល់កល់នេះត្រូវបានគេប្រើដើម្បីបង្ហាញអំពីការដែលពួកខ្មាំងសត្រូវចុះចូលក្រោមបង្គាប់របស់ស្តេច (សូមមើលទំនុកដំកើង ១១០:១)។ ដូច្នេះ ព្រះគឺជាមហាក្សត្រដែលគង់លើហិបសញ្ញាដែលមានចេរូប៊ីន (ខ. ១) និងនៅក្នុងក្រុងស៊ីយ៉ូន (ខ. ២) ហើយមនុស្សគួរតែថ្វាយបង្គំទ្រង់ដោយចុះចូលក្រោមបង្គាប់របស់ទ្រង់។

**ខ. ៦-៩** ទីនេះមិនបានបង្ហាញថា *ម៉ូសេ អើរ៉ុន និងសាំយ៉ូអែល* (ខ. ៦) ជាអ្នកពិសេសដែលមានទំនាក់ទំនងក្នុងសេចក្តីអធិស្ឋានជាមួយព្រះនោះទេ ប៉ុន្តែពួកគេក៏នៅក្នុងចំណោមមនុស្សធម្មតាដែលអធិស្ឋានទៅកាន់ព្រះ ហើយព្រះឆ្លើយតបផងដែរ។ សេចក្តីអធិស្ឋានគឺជាកំណត់សំគាល់ថា យើងគឺជារាស្ត្ររបស់ព្រះនិងមានទំនាក់ទំនងជាមួយទ្រង់។ ពេលរាស្ត្ររបស់ទ្រង់អធិស្ឋានដល់ព្រះនាមទ្រង់ នោះទ្រង់ឆ្លើយតបដោយការមានបន្ទូលមកកាន់ពួកគេ ហើយពួកគេស្តាប់បង្គាប់តាមទ្រង់ (ខ. ៧) ។ ទ្រង់អត់ទោសឲ្យរាស្ត្ររបស់ទ្រង់ ប៉ុន្តែទ្រង់ធ្វើទោសចំពោះអំពើអាក្រក់របស់ពួកគេ (ខ. ៨)។ ទ្រង់មិនអាចអត់ទោសដល់រាស្ត្រទ្រង់ដោយមិនធ្វើទោសដល់អំពើអាក្រក់របស់ពួកគេបានទេ។ ការអត់ទោសដោយមិនធ្វើទោសនឹងនាំឲ្យ

យើងរីករាយចិត្ត ហើយអាចបន្តធ្វើការអាក្រក់ទៀត។ ឯការធ្វើទោសដោយមិនអត់ទោសនឹងនាំឲ្យយើងខឹងនិងអស់សង្ឃឹម។ ដូច្នេះ មហាក្សត្ររបស់យើងនឹងអត់ទោសដល់អស់អ្នកដែលអំពាវនាវដល់ព្រះនាមទ្រង់ ប៉ុន្តែទ្រង់មិនព្រងើយកន្តើយចំពោះអំពើបាបណាមួយរបស់ពួកគេនោះឡើយ គឺរាល់អំពើបាបទាំងអស់របស់ពួកគេត្រូវតែបានកាត់ទោសលើនរណាម្នាក់ជាដាច់ខាត។ ហើយព្រះយេស៊ូវគឺជាកូនចៀមដែលបានផ្ទុកអស់ទាំងអំពើបាបរបស់មនុស្សទាំងអស់ ហើយបានរងទុក្ខសុគតនៅលើឈើឆ្កាងជំនួសយើង។

*ថ្វាយបង្គំនៅត្រង់ភ្នំបរិសុទ្ធ (ខ. ៩)* ភ្នំបរិសុទ្ធឬក្រុងស៊ីយ៉ូន (ខ. ២) សំដៅទៅលើទីក្រុងយេរូសាឡឹម ដែលជាកន្លែងដែលរាស្ត្ររបស់ព្រះនៅក្នុងសញ្ញាចាស់បានថ្វាយបង្គំទ្រង់។

**ការអនុវត្ត:**

ទំនុកដំកើងនេះបង្រៀនថា យើងជារាស្ត្រដែលស្ថិតនៅក្រោមរាជ្យគ្រប់គ្រងរបស់មហាក្សត្រមួយអង្គដ៏បរិសុទ្ធ មានអំណាច សេចក្តីស្រលាញ់ យុត្តិធម៌និងសេចក្តីសុចរិត។ ស្តេចដ៏ជាព្រះទ្រង់សោយរាជ្យ វិនិច្ឆ័យ មានបន្ទូល កាត់ទោសនិងអត់ទោសដល់រាស្ត្ររបស់ទ្រង់។ ទ្រង់គឺជាមហាក្សត្រដែលគង់នៅលើហិបសញ្ញាក្នុងក្រុងយេរូសាឡឹមរបស់ទ្រង់។ ចុះចំណែកយើងដែលជាគ្រីស្ទបរិស័ទក្នុងសតវត្សទី២១នេះ តើយើងគួរតែធ្វើដំណើរទៅក្រុងយេរូសាឡឹមដើម្បីថ្វាយបង្គំព្រះដែរឬទេ? ទេ ព្រះវិហារនិងហិបសញ្ញាលែងមាននៅក្នុងក្រុងយេរូសាឡឹមជាច្រើនពាន់ឆ្នាំមកហើយ។ គ្រីស្ទបរិស័ទមិនថ្វាយបង្គំព្រះនៅក្នុងក្រុងយេរូសាឡឹមទេ។ ព្រះគម្ពីរសញ្ញាថ្មីប្រាប់យើងថា ព្រះយេស៊ូវគឺជាមហាក្សត្រនេះហើយ។ ដូច្នេះ ដើម្បីថ្វាយបង្គំព្រះ យើងត្រូវទៅឯព្រះយេស៊ូវវិញ។ ទ្រង់អត់ទោសបាបដល់អ្នកណាដែលអំពាវនាវដល់ព្រះនាមទ្រង់ (រ៉ូម ១០:៩-១៣)។ ហើយនៅក្នុងសញ្ញាថ្មី ការអំពាវនាវដល់ព្រះនាមទ្រង់ (ទំនុកដំកើង ៩៩:៦) គឺជាការប្រកាសប្រាប់ថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់ (សូមមើល ១កូរិនថូស ១:២)។ តាមរយៈការងារប្រោសលោះរបស់ទ្រង់ ព្រះយេស៊ូវធ្វើជាព្រះលើសអស់ទាំងព្រះនិងជាស្តេចលើសអស់ទាំងស្តេច (១ធីម៉ូថេ ៦:១៥, វិវរណៈ ១៧:១៤, ១៩:១៦) ដែលបានយាងមកគ្រប់គ្រងផែនដីទាំងមូល។ ព្រះវរបិតាបានប្រគល់ទោះទាំងអំណាចនៅស្ថានសួគ៌និងផែនដីមកដល់ទ្រង់ (ម៉ាថាយ ២៨:១៨) ដើម្បីឲ្យទ្រង់សោយរាជ្យនិងវិនិច្ឆ័យដោយសេចក្តីស្រលាញ់ សេចក្តីយុត្តិធម៌ សេចក្តីសុចរិត និងសេចក្តីទៀងត្រង់របស់ទ្រង់។ ហើយភីលីព ២:១០-១១ បង្រៀនយើងយ៉ាងច្បាស់ថា «ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូវ នោះអោយគ្រប់ទាំងជង្គង់នៅស្ថានសួគ៌នៅផែនដី ហើយនៅក្រោមផែនដីត្រូវលុតចុះ ហើយអោយគ្រប់ទាំងអណ្តាតបានថ្លែងប្រាប់ថាព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ សំរាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា»។

យើងគឺជាប្រជារាស្ត្ររបស់មហាក្សត្រដ៏សង្គ្រោះយើងចេញពីអំពើបាប។ ដូច្នេះ យើងគួរតែបន្ទាបខ្លួននៅក្រោមការគ្រប់គ្រងរបស់ទ្រង់ ដាក់ជីវិតរបស់យើងពឹងផ្អែកលើទ្រង់តែមួយ។ ដោយសារមហាក្សត្ររបស់យើងប្រកបដោយសេចក្តីស្រលាញ់ យុត្តិធម៌ សេចក្តីទៀងត្រង់ និងសេចក្តីសុចរិត នោះរាស្ត្រនៅក្នុងនគររបស់ទ្រង់ក៏មានសេចក្តីទាំងនេះនៅក្នុងជីវិតផងដែរ។ ទំនុកដំកើងនេះមិនត្រឹមតែសរសើរតម្កើងដល់ព្រះប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការហៅឲ្យមនុស្សចូលមកសរសើរតម្កើងព្រះផងដែរ។ ដូច្នេះហើយក្នុងនាមយើងជារាស្ត្ររបស់ទ្រង់ យើងមិនត្រឹមតែមានអំណរថ្វាយបង្គំ និងសរសើរតម្កើងដល់ព្រះ

នាមទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែយើងក៏គួរតែហៅពួកអ្នកមិនជឿឲ្យចូលមកសរសើរតម្កើងព្រះផងដែរ ហើយយើងធ្វើការនេះតាមរយៈដំណឹងល្អ។ តើធ្វើដូចម្តេចទើបគ្រប់គ្នាអាចចូលមកក្នុងនគរនេះបាន? អេភេសូរ ២:៨-៩ ប្រាប់ច្បាស់ថា «គឺដោយសារព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសេចក្តីជំនឿជឿលើព្រះយេស៊ូវគ្រីស្ទដែលជាមហាក្សត្រដ៏បរិសុទ្ធរបស់យើងនោះឯង»។ ហើយទីបំផុត យើងទាំងអស់គ្នានឹងបានចូលទៅក្នុងនគរបរិសុទ្ធរបស់ទ្រង់ដែលចុះពីស្ថានសួគ៌មក គឺជាផ្ទៃមេឃថ្មីនិងផែនដីថ្មី ដែលជាយេរូសាឡឹមថ្មីដែលមានព្រះយេស៊ូវ ដែលជាកូនចៀមសុគតជំនួសយើង សោយរាជ្យ និងមានយើងទាំងអស់គ្នាជារាស្ត្រដែលបំរើទ្រង់ ថ្វាយបង្គំទ្រង់ និងសរសើរតម្កើងដល់ព្រះនាមទ្រង់នៅអស់កល្បជានិច្ច (វិវរណៈ ២១, ២២)។ ហើយនេះគឺជាអ្វីដែលគ្រីស្ទបរិស័ទ្ធគ្រប់រូបទន្ទឹងរង់ចាំ!

### ឯកសារយោងៈ

Carson, D. A., France, R. T., Motyer, J. A., & Wenham, G. J. (Eds.). (1994). *New Bible commentary: 21st century edition* (4th ed., pp. 549–550). Leicester, England; Downers Grove, IL: Inter-Varsity Press.

Matthews, V. H., Chavalas, M. W., & Walton, J. H. (2000). *The IVP Bible background commentary: Old Testament* (electronic ed., Ps 98:9–99:5). Downers Grove, IL: InterVarsity Press.

Kidner, D. (1975). *Psalms 73–150: An Introduction and Commentary* (Vol. 16, pp. 386–388). Nottingham, England: Inter-Varsity Press.